ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន០១លើក។

១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា លើកទី១១ នីតិកាលទី៤ ចំនួន០១លើក។

១.១.២-បដិសណ្ឋារកិច្ចខ្សែជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **សាន់តូ ដាម៉ូស៊ូម៉ាតូ** Santo Damosumarto ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យលោកជំទាវ SHEN Yueyue អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រឹក្សានយោបាយប្រជាជនចិន និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

១.១.៣-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ សមាជិក-សមាជិកាក្រុមប្រឹក្សាសង្កាត់ ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ។

១.១.៤-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមដង្ហែ និងទទួលព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងបំពេញព្រះរាជទស្សនកិច្ចផ្លូវការ និងយាងចូលរួមសន្និសីទអន្តររដ្ឋាភិបាលលើកទី៤ ស្តីពីរមណីយដ្ឋានប្រវត្តិសាស្ត្រតំបន់អភិរក្ស



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (855 23) 211 441, 211 442, 211 443 ទូរសារ៖ (855 23) 211 446, E-mail: oum_sarith@camnet.com.kh

អង្គរ នៅសាធារណរដ្ឋបារាំង

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តសៀមរាប

-បានអញ្ជើញជាគណៈអធិបតីដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍ លើកទី៧០ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា រួមនិងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ និងចូលរួមមីទ្ទិញមហាជន នៅមុខព្រះបរមរាជវាំង

-បានអញ្ជើញជាគណៈអធិបតីដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ទៀនជ័យ នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភានីតិកាលទី៤ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកា **យិប ចាំកេសន** ដែលត្រូវជាម្តាយក្មេករបស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅខេត្តកោះកុង

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **អ៊ុក សុជាតិ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅគេហដ្ឋាន ខណ្ឌចំការមន រាជធានីភ្នំពេញ។

១.១.៨-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន២៧ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១០ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា**

-បានបំពេញភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន០១លើក។

១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក និងចូលរួមកិច្ចប្រជុំ

ពេញអង្គព្រឹទ្ធសភា លើកទី១១ នីតិកាលទី៤ ចំនួន០១លើក។

១.២.២-បដិសណ្ឋារកិច្ចឡៀវជាតិ-អន្តរជាតិ

-បានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ SHEN Yueyue អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញទទួល និងរៀបចំពិធីលៀងសាយភោជនផ្លូវការជូនជាកិត្តិយសដល់លោកជំទាវ SHEN Yueyue អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

១.២.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន២៥ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា លើកទី១១ នីតិកាលទី៤ ចំនួន០១លើក។

១.៣.២-សកម្មភាពចុះមូលដ្ឋាន

-បានចាត់ឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ ព្យាបាលជំងឺប្រគេនព្រះសង្ឃ និងជូនប្រជាពលរដ្ឋ នៅក្នុងឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ និងភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ" និងបុព្វការីជន ក្នុងឱកាសនៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ ក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៧០ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ និងចូលរួមមីទ្ទិញមហាជន នៅមុខព្រះបរមរាជវាំង

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងមហាសន្និបាតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជាលើកទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ

-បានអញ្ជើញអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកា **យិប ចាំកេសន** ដែលត្រូវជាម្តាយក្មេករបស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅខេត្តកោះកុង។

១.៣.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៣២ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញ លើសេចក្តីព្រាងច្បាប់ ចំនួន០៣ច្បាប់។

## ៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំពេញអង្គ លើកទី១១ នីតិកាលទី៤ ចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន០៣ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

២-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃអេមីរ៉ាតអារ៉ាប់រួម។

## ៤-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន០៣ច្បាប់។

### ៤.២-មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពី ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនបរទេស និងពិនិត្យស្ថានភាពចេញ-ចូលរបស់ភ្ញៀវជាតិ អន្តរជាតិ កិច្ចសហប្រតិបត្តិការ ភាពងាយស្រួល និងបញ្ហាប្រឈមនានា នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ និងបានអញ្ជើញទស្សនកិច្ចប្រាសាទកោះកេរ្ត៍ ដើម្បីឈ្វេងយល់អំពីការគ្រប់គ្រងកិច្ចអភិរក្ស និងការអភិវឌ្ឍវិស័យទេសចរណ៍ នៅស្រុកគូលែន ខេត្តព្រះវិហារ

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព នៅខេត្តកំពង់ស្ពឺ។

### ៤.៣-មុខងារតំណាង

-បានទទួលពាក្យបណ្តឹង ចំនួន០៤ករណី កំពុងពិនិត្យសិក្សា ចំនួន០១ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីក្រសួង ចំនួន០១ករណី កំពុងពិនិត្យសិក្សាបាន ចំនួន០៤ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន០២ករណី

-បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយសេចក្តីអង្កេតសន្និដ្ឋាន នៃរបាយការណ៍លើកទី២ របស់ប្រទេសកម្ពុជា ស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រៀបចំដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) សហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR) នៅសណ្ឋាគាររ៉ាហ្វល ឡឺរ៉ូយ៉ាល់

-បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ នៅវិមានរដ្ឋសភា

-បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ពិធីស្វាគមន៍ និងផ្តល់ព័ត៌មានសេវាសំខាន់ៗជូនតំណាងរាស្ត្រ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា

-បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយអាហារូបករណ៍ និងវគ្គ

សិក្សារយៈពេលខ្លី ទៅបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ជូនសិស្ស-និស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់បណ្ឌិត នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចំនួន៤០០នាក់

-បានអញ្ជើញចូលរួមវេទិកាជាតិស្តីពី ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ក្រោមប្រធានបទ ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ និងសាធារណៈ នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ

-បានអញ្ជើញទទួលជួបសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មកពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន៥០០នាក់ អញ្ជើញមកទស្សនកិច្ច និងសិក្សាឈ្វេងយល់អំពីការថែទាំដំណាំកសិកម្ម ប្រព័ន្ធប្រឡាយទឹក ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់កសិទេសចរណ៍ ម៉ុង ឫទ្ធីសែនជ័យ

-បានអញ្ជើញផ្តល់បទសម្ភាសន៍ អំពីវឌ្ឍនភាពរបស់ព្រឹទ្ធសភានីតិកាលទី៤ ជូនទូរទស្សន៍ជាតិកម្ពុជា(ទទក) នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ជូនដល់សាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង ចំនួន១៩នាក់ អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញនាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យ ទៅប្រគេនព្រះសង្ឃ ក្នុងឱកាសនៃពិធីបុណ្យកឋិនទាន នៅតាមវត្តអារាម នៅរាជធានីភ្នំពេញ និងបណ្តាខេត្តក្រុងនានា

-បានអញ្ជើញចូលរួមពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា នៅចុងនីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមពិធីថ្វាយកម្រងផ្កា គោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ " និងគោរពព្រះវិញ្ញាណក្ខន្ធបុព្វការីជន ក្នុងឱកាសនៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ទៀនជ័យ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧០ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅមុខព្រះបរមរាជវាំង

-បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរមហាសន្និបាតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជាលើកទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ

-បានអញ្ជើញចូលរួមពិធីដាក់ឱ្យប្រើប្រាស់ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន២០២៣-២០២៨ និងយុទ្ធនាការផ្ទៃមេឃពណ៌ខៀវ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្មើសូន្យ Net Zero នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន០៩លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម និងខេត្តព្រះសីហនុ

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ជួយប្រជាពលរដ្ឋជួបគ្រោះធម្មជាតិ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន៧០លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន១៦២លើក។

## ៤.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៣១ (APPF-31) នៅទីក្រុង Pasay នៃរដ្ឋធានីម៉ានីល សាធារណរដ្ឋហ្វីលីពីន

-បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារសើរើលក្ខន្តិកៈAPF នៅទីក្រុងហ្សឺណែវ (Genève) ប្រទេសស្វីស Suisse។

-បានអញ្ជើញទទួល និងជូនដំណើរលោកជំទាវ SHEN Yueyue អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញចូលរួមអបអរសាទរក្នុងឱកាសខួបលើកទី១០០ឆ្នាំ នៃការប្រកាសសាធារណរដ្ឋទួកគី នៅស្ថានទូតសាធារណទួកគីប្រចាំនៅកម្ពុជា នៅរាជធានីភ្នំពេញ។៕

ថ្ងៃ ចន្ទ ១៤ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ